00198938

C22/I/57

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 07 / 2008
ម៉ោង (Time/Heure): 10:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**កាលបរិច្ឆេទ:** ៨ កក្កដា ២០០៨

---

# សេចក្តីសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំវិធានការការពារក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចការឃុំខ្លួនបណ្តោះអាសន្ន

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

PRE-TRIAL CHAMBER PRELIMINAIRE ECCC

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) បានទទួលសំណើពីសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំវិធានការការពារ (“សំណើ”) ក្នុងសវនាការបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

២. តាងឱ្យនាមដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប សហមេធាវីបានស្នើសុំកុំឱ្យលើកឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាសាធារណៈ និងស្នើសុំលុបឈ្មោះទាំងនេះចេញពីកំណត់ហេតុ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីថ្លែងប្រាស្រ័យដោយខ្លួនឯងក៏ដោយ។ សហមេធាវីបានស្នើសុំបន្តទៀតថា លេខសម្គាល់គួរផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីនិមួយៗ ដើម្បីប្រើប្រាស់ជាសាធារណៈ។

៣. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ដើមបបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ច្បាស់ថា ខ្លួនមិនចង់ឱ្យលើកឈ្មោះរបស់ខ្លួនជាសាធារណៈក្នុងពេលសវនាការ។ មុនពេលសវនាការ អង្គបុរេជំនុំជម្រះមិនត្រូវបានជម្រាបអំពីបញ្ហានេះ ហើយមិនបានដឹងអំពីបំណងរបស់ភាគីដទៃទៀតក្នុងការលាតត្រដាងអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

៤. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបានសម្រេចមុនពេលសវនាការថា ឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងនៅក្នុងសំណើ នឹងត្រូវបានរក្សាការសម្ងាត់ក្នុងពេលសវនាការ តាមការស្នើសុំ។

៥. តម្រូវការក្នុងការប្រើប្រាស់រហស្សនាមចំពោះដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានកំណត់មុនពេលសវនាការ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យថ្លែងប្រាស្រ័យ តាមរយៈមេធាវីរបស់ខ្លួនប៉ុណ្ណោះ ដូចដែលបានសម្រេចសេចក្តីលើកមុន។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

អនុញ្ញាតតាមសំណើក្នុងការស្នើសុំរក្សាឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាសម្ងាត់ ដែលជាការស្នើសុំវិធានការការពារក្នុងគោលបំណងសម្រាប់សវនាការនិងការចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍។ ៕

ភ្នំពេញ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC

ប្រាក់ គីមសាន